ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ....... សហវ.

# ប្រកាស
## ស្តីពី
## ការណែនាំអនុវត្តពន្ធកាត់ទុកលើការបែងចែកភាគលាភ

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៦/០១៩ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

### ប្រការ ១.- គោលបំណង

ប្រកាសនេះ មានគោលបំណងណែនាំអនុវត្តពន្ធកាត់ទុកលើការបែងចែកភាគលាភ ដូចមានចែងក្នុងមាត្រា ២៦ ថ្មី (មួយ) និងមាត្រា៣៣ ថ្មី នៃច្បាប់ស្តីពីសារពើពន្ធ។

### ប្រការ ២.- គោលដៅ

ប្រកាសនេះ មានគោលដៅដាក់ចេញនូវវិធានសម្រាប់កំណត់អំពីការអនុវត្តពន្ធកាត់ទុកលើការបែងចែកភាគលាភ ដែលអ្នកជាប់ពន្ធនិវាសនជនទូទាត់ឱ្យទៅអ្នកជាប់ពន្ធអនិវាសនជន។

### ប្រការ ៣.- វិសាលភាព

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសដែលប្រកបអាជីវកម្មក្នុងព្រះរាជាណាចក្រកម្ពុជា។

### ប្រការ ៤.- និយមន័យ

អនុលោមតាមមាត្រា៣ ថ្មី នៃច្បាប់ស្តីពីសារពើពន្ធ ពាក្យ "ភាគលាភ" សំដៅដល់ចំណែកជាសាច់ប្រាក់ឬជាទ្រព្យ ដែលនីតិបុគ្គលបានចែកឱ្យអ្នកចូលហ៊ុនទៅតាមកម្រិតនៃភាគកម្មរបស់ខ្លួននៅក្នុងដើមទុនផ្ទាល់របស់នីតិបុគ្គល លើកលែងតែការបែងចែកមូលធនឬដើមទុនក្នុងពេលជម្រះបញ្ជីរំលាយក្រុមហ៊ុន។ ចំណែកណាមួយដែលចាត់ទុកថាជាភាគលាភឬមិនមែនជាភាគលាភ ត្រូវផ្អែកតាមលក្ខខណ្ឌខាងលើនេះដោយពុំគិតថា នីតិបុគ្គលមានឬគ្មានប្រាក់ចំណូលសុទ្ធក្នុងឆ្នាំចរន្តឬពីឆ្នាំមុនៗឡើយ។

### ប្រការ ៥.- ពន្ធកាត់ទុកលើការបែងចែកភាគលាភ

១- ការបែងចែកប្រាក់ចំណូលរក្សាទុកឱ្យទៅអ្នកចូលហ៊ុនស្របតាមលក្ខខណ្ឌដូចមានចែងក្នុងប្រការ៤ នៃប្រកាសនេះ ត្រូវចាត់ទុកថាជាការបែងចែកភាគលាភ។

២- អនុលោមតាមមាត្រា២៦ ថ្មី (មួយ) និងមាត្រា៣៣ ថ្មី នៃច្បាប់ស្តីពីសារពើពន្ធ ភាគលាភដែលបានបែងចែកដោយអ្នកជាប់ពន្ធនិវាសនជនឱ្យទៅអ្នកជាប់ពន្ធអនិវាសនជន ត្រូវជាប់ពន្ធកាត់ទុកតាមអត្រា ១៤ ភាគរយ នៃទឹកប្រាក់ត្រូវបើក។

### ប្រការ ៦.- ការបង្វែរប្រាក់ចំណូលរក្សាទុកទៅក្នុងមូលធនឬដើមទុន

១- ការបង្វែរចំណែកណាមួយឬទាំងស្រុងនៃប្រាក់ចំណូលរក្សាទុកទៅក្នុងមូលធនឬដើមទុនរបស់សហគ្រាស មិនត្រូវបានចាត់ទុកជាការបែងចែកភាគលាភ និងមិនជាប់ពន្ធកាត់ទុកទេ។

២- ការបង្វែរប្រាក់ចំណូលរក្សាទុកទៅក្នុងមូលធនឬដើមទុន ត្រូវបានចាត់ទុកថាបានធ្វើឡើងត្រឹមត្រូវ ប្រសិនបើសហគ្រាសបានបំពេញលក្ខខណ្ឌ ដូចខាងក្រោម÷

ក- មានការសម្រេចពីក្រុមប្រឹក្សាភិបាលរបស់សហគ្រាស

ខ- មានភស្តុតាងច្បាស់លាស់អំពីការកែប្រែមូលធនដោយមានការទទួលស្គាល់ពីស្ថាប័នមានសមត្ថកិច្ច។

**ប្រការ ៧.- ការលក់ភាគហ៊ុន ឬការបែងចែកមូលធនឬដើមទុន ដែលបានពីការបង្វែរប្រាក់ចំណូលរក្សាទុក**

ក្នុងករណីសហគ្រាសធ្វើការលក់ភាគហ៊ុន ឬបែងចែកមូលធនឬដើមទុនទោះក្នុងពេលប្រកបអាជីវកម្មឬពេលជម្រះបញ្ជីរំលាយក្រុមហ៊ុនក្តី ចំណែកភាគហ៊ុន ឬមូលធនឬដើមទុន ដែលបានមកពីការបង្វែរចេញពីប្រាក់ចំណូលរក្សាទុក ត្រូវជាប់ពន្ធកាត់ទុកតាមមាត្រា២៦ ថ្មី (មួយ) នៃច្បាប់ស្តីពីសារពើពន្ធ។

**ប្រការ ៨.- ភាតព្វកិច្ចរបស់ភ្នាក់ងារកាត់ទុក**

សហគ្រាសដែលបានធ្វើការទូទាត់ភាគលាភឱ្យទៅអ្នកជាប់ពន្ធអនិវាសនជន ត្រូវដាក់លិខិតប្រកាស និងបង់ប្រាក់ពន្ធដែលបានកាត់ទុកជូនរដ្ឋបាលសារពើពន្ធ ទៅតាមទម្រង់ដែលរដ្ឋបាលសារពើពន្ធបានកំណត់យ៉ាងយឺតបំផុតត្រឹមថ្ងៃទី ២០ នៃខែបន្ទាប់ពីខែដែលបានធ្វើការទូទាត់។

សម្រាប់គោលដៅនៃពន្ធកាត់ទុក ទឹកប្រាក់ភាគលាភដែលបានកត់ត្រាបែងចែកក្នុងបញ្ជីគណនេយ្យ ត្រូវចាត់ទុកថាបានទូទាត់។

**ប្រការ ៩.- ការអនុវត្ត**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៧

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- ដូចប្រការ ៩ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ